Australian Aid | ASEAN-Australia Counter Trafficking

*បកប្រែក្រៅផ្លូវការ*

ថ្ងៃទី ១២ ខែឧសភា ឆ្នាំ២០២១

**សូមគោរពជូន**
**លោកជំទាវ ជូ ប៊ុនអេង**
**រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ**
**អនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**
**ព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ:** កម្មវិធីអាស៊ានមនុស្សការជួញដូរប្រឆាំងអូស្ត្រាលី- (ASEAN-ACT) - ការវិភាគអំពីការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងនឹងអំពើជួញដូរមនុស្ស (ACTIP) ពាក់ព័ន្ធនឹងកិច្ចការពារជនរងគ្រោះដោយការជួញដូរក្នុងតំបន់អាស៊ាន។

យោងកម្មវត្ថុខាងនេះ ខ្ញុំមានកិត្តយសស្នើសូមការគាំទ្ររបស់**លោកជំទាវ** អញ្ជើញអ្នកជំនាញមកពីក្រសួង / ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាលកម្ពុជាចូលរួមផ្តល់បទសម្ភាសន៍ ដែលនឹងត្រូវអនុវត្តដោយដៃគូនៃកម្មវិធីអាស៊ានអូស្ត្រាលី-មនុស្សការជួញដូរប្រឆាំង )ASEAN-ACT (រ៉ាភីតអេសៀ )Rapid Asia( ។

ស្ថិតក្រោមវិសាលភាពសកម្មភាពនេះ កម្មវិធីអាស៊ាន )មនុស្សការជួញដូរប្រឆាំងអូស្ត្រាលី-ASEAN-ACT( បានសហការជាមួយក្រុមហ៊ុនឈ្មោះ រ៉ាភីតអេសៀ ) Rapid Asia (ដែលជាក្រុមហ៊ុនឯករាជ្យផ្តល់សេវាកម្មប្រឹក្សាការងារ ដើម្បីធ្វើការវិភាគស្តីពីការការពារជនរងគ្រោះពីអំពើជួញដូរមនុស្សក្នុងតំបន់អាស៊ាន ដោយផ្អែកលើទស្សនៈថាសិទ្ធិរបស់ជនរងគ្រោះ និងកិច្ចការពារជនរងគ្រោះគឺមានសារសំខាន់ខ្លាំងបំផុត ក្នុងការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សពិសេសស្ត្រី និងកុមារ )ACTIPទាំង( នៅថ្នាក់ជាតិ និងថ្នាក់តំបន់។

ការវិភាគនេះ មានបំណងសំដៅគាំទ្រការអនុវត្តអនុសញ្ញា ACTIP និងផ្តល់ការវាយតម្លៃដែលមានភាពច្បាស់លាស់ ត្រឹមត្រូវលើការអនុវត្តបច្ចុប្បន្ន ការប្រតិបត្តិល្អ និងអនុសាសន៍នានា ដើម្បីធ្វើឱ្យប្រសើរឡើងនៅក្នុងការឆ្លើយតបទៅនឹងកិច្ចការពារជនរងគ្រោះ។ ដើម្បីអនុវត្តការងារនេះ ក្រុមការងារ រ៉ាភីតអេសៀ ) Rapid Asia ( ចាំបាច់ត្រូវសម្ភាសភាគីពាក់ព័ន្ធផ្សេងៗ មានដូចជាមន្ត្រីក្នុងជួររាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលក្នុងប្រទេសកម្ពុជា។

ក្នុងន័យនេះ ខ្ញុំសូមគោរពស្នើសុំគណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្ស (គ.ជ.ប.ជ) សូមមេត្តាជួយក្នុងការអញ្ជើញមន្ត្រីពាក់ព័ន្ធសំខាន់ៗមកពីក្រុមការងារអន្តរក្រសួងនៃ (គ.ជ.ប.ជ) ដើម្បីជួបជាមួយអ្នកពិគ្រោះការ រ៉ាភីតអេសៀ (Rapid Asia) ដើម្បីធ្វើសម្ភាសន៍ KII នេះ។ យើងសូមភ្ជាប់ជាមួយនូវបញ្ជីឈ្មោះអ្នកពាក់ព័ន្ធសំខាន់ៗ ជាមួយកាលវិភាគ ស្នើសុំជួបប្រជុំដាច់ដោយឡែកជាមួយស្ថាប័ន/ទីភ្នាក់ងាររដ្ឋាភិបាលនីមួយៗ តាមរយៈអនឡាញ។ ប្រសិនបើលោក

ជំទាវត្រូវការព័ត៌មានបន្ថែមទាក់ទងនឹងការងារវិភាគនេះ សូមទាក់ទងមន្ត្រីកម្មវិធីយើងគឺ លោក អ៊ុន វុទ្ធី តាមរយៈទូរស័ព្ទលេខ: ០៧៧ ៨៤៤ ៩៧៧, អ៊ីមែល: vuthy.un@aseanact.org

ជាទីបញ្ចប់ នាងខ្ញុំសូមឆ្លៀតឱកាសនេះ ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកជំទាវ និង គ.ជ.ប.ជ ចំពោះការគាំទ្រដល់កាស្រាវជ្រាវនេះ និងក៏ដូចជាការសហការគាំទ្រដ៏ល្អរបស់លោកជំទាវរហូតមកដល់ពេលនេះជាមួយនឹងកម្មវិធី ហើយយើងទន្ទឹងរង់ចាំធ្វើការជាមួយគ្នាបន្តទៀតយ៉ាងជិតស្និទ្ធក្នុងការអនុវត្តកម្មវិធី ASEAN-ACT។

សូម**លោកជំទាវ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

[ហត្ថលេខា]

Kate McCubbin
ប្រធានក្រុម
ASEAN-ACT

ចម្លងជូន: **ឯកឧត្តម ប៉ែន ពេជ្រសាលី** អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ ក្រសួងយុត្តិធម៌ និងជាប្រធានគណៈកម្មាធិការដឹកនាំកម្មវិធីថ្នាក់ជាតិ (NPSC) នៃកម្មវិធីអាស៊ាន -អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស។

ឯកសារជូនភ្ជាប់: - សេចក្តីសង្ខេបអំពីគម្រោងស្រាវជ្រាវអំពីការអនុវត្តកិច្ចការពារជនរងគ្រោះក្នុងតំបន់អាស៊ាន
- បញ្ជីឈ្មោះអ្នកពាក់ព័ន្ធសំខាន់ៗជាមួយកាលវិភាគ ស្នើសុំជួបប្រជុំជាច់ដោយឡែកជាមួយស្ថាប័នរាជរដ្ឋាភិបាលនីមួយៗ តាមរយៈអនឡាញជាមួយក្រុមការងារ៉ាភីតអេសៀ (Rapid Asia)។

ឯកភាព

18/05/21

ជូ_ម៉ុនអេង

Australian Aid | ASEAN-Australia Counter Trafficking

**កម្មវិធី ASEAN ACT៖**

**ការស្រាវជ្រាវអំពីការអនុវត្តកិច្ចការពារជនរងគ្រោះក្នុងតំបន់អាស៊ាន**

**សេចក្ដីសង្ខេបអំពីគម្រោង**

## សនិទានភាព

អនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្ស (ACTIP) ដែលបានចូលជាធរមាននៅថ្ងៃទី ០៨ ខែមីនា ឆ្នាំ២០១៧ គឺជាអនុសញ្ញាជាប្រវត្តិសាស្ត្រមួយ និង ជាជំហានមួយដ៏សំខាន់ក្នុងការអភិវឌ្ឍក្របខ័ណ្ឌច្បាប់មួយដែលរឹងមាំជាងមុន ដើម្បីប្រឆាំងនឹងអំពើជួញដូរមនុស្ស (TIP) នៅក្នុងបណ្ដារដ្ឋជាសមាជិកអាស៊ាន (AMSs)។ គោលបំណងស្នូលរបស់ ACTIP ទទួលស្គាល់សេចក្ដីត្រូវការឱ្យមានការពង្រឹងការអនុវត្តច្បាប់ និង ចំណាត់ការបែបសហការដោយមានការសម្របសម្រួលកាន់តែខ្លាំងក្លាបន្ថែមទៀតនៅក្នុងតំបន់ ដើម្បីបង្ការអំពើជួញដូរ និង ការពារ ព្រមទាំងជួយដល់ជនរងគ្រោះឱ្យបានកាន់តែប្រសើរ។ គោលដៅរួមរបស់ ACTIP គឺសំដៅធានាថារដ្ឋជាសមាជិកអាស៊ានមានប្រព័ន្ធយុត្តិធម៌ប្រកបដោយប្រសិទ្ធភាព ដែលកំណត់ដាក់ទណ្ឌកម្មប្រកបដោយភាពយុត្តិធម៌ទៅលើជនល្មើសជួញដូរ និង ការពារសិទ្ធិមនុស្សរបស់ជនរងគ្រោះនៃអំពើជួញដូរ។ ការអនុវត្ត ACTIP បានទទួលមគ្គុទ្ទេសក៍ណែនាំពីផែនការសកម្មភាពអាស៊ានប្រឆាំងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ។ បើទោះជាដូច្នេះក្ដី មានសំណួរជាច្រើនអំពីលទ្ធភាពក្នុងការអនុវត្តអនុសញ្ញា ការត្រួតពិនិត្យលើអនុលោមភាពរបស់រដ្ឋជាសមាជិក និង អាស៊ាន និង ការដោះស្រាយអសង្គតិភាពរវាងច្បាប់ជាតិ និង ការប្ដេជ្ញាចិត្តរបស់រដ្ឋជាសមាជិកអាស៊ាន ដែលត្រូវបានធ្វើឡើងក្រោម ACTIP។

កម្មវិធី ASEAN-ACT បានជួលក្រុមហ៊ុន Rapid Asia ឱ្យធ្វើការស្រាវជ្រាវអំពីកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរនៅអាស៊ាន ជាមួយនឹងទស្សនៈយល់ឃើញថា សិទ្ធិនិងកិច្ចការពារជនរងគ្រោះមានសារៈសំខាន់ខ្លាំងណាស់ចំពោះការអនុវត្តអនុសញ្ញា ACTIP នៅថ្នាក់តំបន់ និង ថ្នាក់ជាតិ។ ការស្រាវជ្រាវនេះនឹងត្រូវបានធ្វើឡើងនៅក្នុងរដ្ឋជាសមាជិកអាស៊ានចំនួន៧ រួមមាន កម្ពុជា ឥណ្ឌូនេស៊ី ឡាវ មីយ៉ាន់ម៉ា ហ្វីលីពីន ថៃ និង វៀតណាម។ ការសិក្សានេះមានគោលបំណងគាំទ្រដល់ការអនុវត្តអនុសញ្ញា ACTIP ផ្ដល់នូវការវាយតម្លៃមួយដែលមានភាពសុក្រឹត្យ និង មានបច្ចុប្បន្នភាពអំពីការអនុវត្តបច្ចុប្បន្ន ការអនុវត្តល្អ និង អនុសាសន៍សម្រាប់ធ្វើការកែលម្អ ដើម្បីឆ្លើយតបទៅនឹងកិច្ចការពារជនរងគ្រោះ។

## គោលបំណង

គោលបំណងជារួមនៃការស្រាវជ្រាវនេះ គឺសំដៅកំណត់កម្រិតដែលការសម្រេចបាននូវសិទ្ធិជនរងគ្រោះសម្រាប់ជនដែលត្រូវបានគេជួញដូរត្រូវបានអនុវត្តនៅក្នុងអាស៊ាន ក្នុងបរិបទនៃកាតព្វកិច្ចក្រោមអនុសញ្ញា ACTIP ជាមួយគោលបំណងជាក់លាក់ដូចខាងក្រោម៖

១. ដើម្បីពិនិត្យទៅលើការអនុវត្តដែលមានស្រាប់ទៅលើអនុសញ្ញា ACTIP ទាក់ទងនឹងកិច្ចការពារជនរងគ្រោះ ពាក់ព័ន្ធនឹងសិទ្ធិជនរងគ្រោះ សមភាព និង បរិយាប័ន្ននៅក្នុងការឆ្លើយតបផ្នែកយុត្តិធម៌របស់រដ្ឋជាសមាជិកអាស៊ាន រាប់បញ្ចូលទាំងមុនពេល និង ក្នុងអំឡុងពេលនៃការផ្ទុះរាលដាលនៃជំងឺកូវីដ១៩។

២. ដើម្បីកំណត់រក និង វាយតម្លៃហានិភ័យ/បញ្ហាប្រឈម ដែលក្រុម និងបុគ្គលប្រឈមទៅនឹងការមិនសូវទទួលបានការយកចិត្តទុកដាក់ (ដូចជា ស្ត្រី កុមារ ក្រុមស្រឡាញ់ភេទដូចគ្នា ជនជាតិដើមភាគតិច ជនពិការ និង ក្រុម

ដទៃទៀតនៅក្នុងសង្គម) បានជួបប្រទះ ក្នុងការរកបាន ការទទួលបានដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ និង កិច្ចការពារជនរងគ្រោះប្រកបដោយគុណភាព មុនពេល និង ក្នុងអំឡុងពេលនៃការរាតត្បាតជំងឺកូវីដ១៩។

៣. ដើម្បីជូនដំណឹងដល់អ្នកពាក់ព័ន្ធនានាអំពីការអនុវត្តល្អ និង ភាពមានកម្រិតដែលកើតមាន ដើម្បីបង្ការ កាត់បន្ថយ និង ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស ស្របតាមកាតព្វកិច្ចក្រោមអនុសញ្ញា ACTIP ទាក់ទងនឹងកិច្ចការពារជនរងគ្រោះ។

## ការរៀបចំនិងវិធីសាស្ត្រស្រាវជ្រាវ




ការពិនិត្យឯកសារ៖ ការពិនិត្យឯកសារនឹងជួយកំណត់រកប្រភពទិន្នន័យដែលមានស្រាប់ និង របាយការណ៍ថ្មីៗ ដែលបានពិនិត្យមើលស្ថានភាពនៃអំពើជួញដូរមនុស្សនៅក្នុងរដ្ឋជាសមាជិកអាស៊ានទាំង៧ ដោយផ្តោតការយកចិត្តទុកដាក់ជាក់លាក់ទៅលើការបន្សុំអនុសញ្ញា ACTIP នៅក្នុងច្បាប់ និង គោលនយោបាយជាតិពាក់ព័ន្ធនឹងកិច្ចការពារជនរងគ្រោះ ការកត់ត្រាព័ត៌មានជុំវិញការអនុវត្ត និង របៀបដែលកិច្ចការពារជនរងគ្រោះកំពុងត្រូវបានអនុវត្ត។

កិច្ចសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ (KII)៖ វិធីសាស្ត្រជ្រើសរើសសំណាកដោយមានគោលដៅ និង វិធីសាស្ត្រជ្រើសរើសសំណាកដែលជាអ្នកឯកទេស នឹងត្រូវយកមកប្រើប្រាស់ ដើម្បីកំណត់រកអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដោយផ្អែកលើព័ត៌មានដែលទទួលបានពីអ្នកគ្រប់គ្រងប្រចាំប្រទេសនៃកម្មវិធី ASEAN-ACT និង ការពិនិត្យឯកសារ។ គេបានប្រមើលថាកិច្ចសម្ភាសន៍ទាំងនេះ អាចធ្វើឡើងបានតាមរយៈជំនួបផ្ទាល់ ឬ តាមរយៈអនឡាញ ក្នុងទម្រង់ជាកិច្ចសម្ភាសន៍លក្ខណៈរៀបចំមុនពាក់កណ្តាល ជាមួយនឹងការច្របាច់បញ្ចូលគ្នានូវសំណួរបើក និង សំណួរបិទ។

ការវិភាគទិន្នន័យ ការអនុវត្តត្រីកោណវិធាន និង សេចក្តីព្រាងនៃគំហើញពីការស្រាវជ្រាវ៖ សេចក្តីសង្ខេបនៃកិច្ចសម្ភាសន៍ និងការពិនិត្យឯកសារ នឹងត្រូវយកមកធ្វើការវិភាគ និង គំហើញដែលមានភាពពាក់ព័ន្ធនឹងត្រូវលើកឡើង ព្រមទាំងភ្ជាប់ត្រឡប់ទៅនឹងគោលបំណងនៃការស្រាវជ្រាវដែលបានកំណត់។ នៅពេលដែលទិន្នន័យពីច្រើនប្រភពត្រូវបានយកមកប្រើប្រាស់ ការអនុវត្តត្រីកោណវិធានមានសារៈសំខាន់ក្នុងការធានាថាអនុសាសន៍ មានសង្គតភាព និង មានការគាំទ្រពីទិន្នន័យដែលគួរឱ្យជឿជាក់បាន។ បន្ទាប់មក គំហើញសំខាន់ៗនឹងត្រូវយកមកផ្ទៀងផ្ទាត់ធៀបទៅនឹងគំហើញពីការពិនិត្យឯកសារ។ ដំណើរការត្រីកោណវិធាន មានរៀបរាប់ជាលក្ខណៈរចនាសម្ព័ន្ធដូចខាងក្រោម។




## កិច្ចដំណើរការផ្ទៀងផ្ទាត់បញ្ជាក់

សេចក្តីព្រាងនៃគំហើញពីការស្រាវជ្រាវ នឹងត្រូវយកមកចែករំលែក និង បង្ហាញជូនដល់អ្នកពាក់ព័ន្ធទាំងអស់នៅក្នុងសិក្ខាសាលាពិនិត្យផ្ទៀងផ្ទាត់ក្នុងប្រទេស ដើម្បីប្រមូលយកធាតុចូល និង យោបល់គ្រប់នានា ដើម្បីដាក់បញ្ចូលទៅក្នុងរបាយការណ៍ចុងក្រោយ។

**ក្រុមគោលដៅ**

ក្រសួងពាក់ព័ន្ធរបស់រដ្ឋាភិបាល៖

- មន្ត្រីយុត្តិធម៌ (ក្រសួងច្បាប់ និងយុត្តិធម៌ ការិយាល័យអគ្គមេធាវី នគរបាលជាតិ តុលាការកំពូល និង ទីភ្នាក់ងារយុត្តិធម៌ពាក់ព័ន្ធ)
- ក្រុមការងារប្រឆាំងការជួញដូរ (ATTF) ឬ គណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្ស (ទីភ្នាក់ងារនាំមុខ)
- មន្ត្រីរដ្ឋាភិបាលពាក់ព័ន្ធ (ក្រសួងសុខុមាលភាពសង្គម ក្រសួងកិច្ចការនារី (និងកុមារ) ក្រសួងការងារ នាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងការបរទេស
- គណៈកម្មការជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRC) គណៈកម្មការជាតិទទួលបន្ទុកអំពើហិង្សាលើស្ត្រី គណៈកម្មការជាតិទទួលបន្ទុកកិច្ចការពារកុមារ
- ទីភ្នាក់ងារការពារសាក្សី និងជនរងគ្រោះ ឬ អ្នកសម្របសម្រួលជនរងគ្រោះ/សាក្សី
- អ្នកតំណាងនៃគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ាន ទទួលបន្ទុកសិទ្ធិមនុស្ស (AICHR)
- អ្នកតំណាងនៃគណៈកម្មការអាស៊ានទទួលបន្ទុកការលើកកម្ពស់ និង កិច្ចការពារសិទ្ធិស្ត្រី និង កុមារ (ACWC)

អង្គការសង្គមស៊ីវិល (CSOs) និងវិស័យឯកជន

- CSOs ដែលកំពុងធ្វើការងារលើបញ្ហាកិច្ចការពារ និងផ្តល់ជំនួយដល់ជនរងគ្រោះ
- មេធាវី និង ជំនួយផ្នែកច្បាប់

**ពេលវេលា៖**

មានរយៈពេល៦ខែ ៖ កុម្ភៈ ២០២១ – កក្កដា ២០២១

# បញ្ជីអ្នកពាក់ព័ន្ធថ្នាក់ជាតិ (កម្ពុជា) ដែលនឹងត្រូវជួបសម្ភាសន៍

| ល.រ | ថ្ងៃ និងពេលវេលាសុំជួប | ស្ថាប័ន |
|---|---|---|
| ១ | ២៤/០៥/២០២១<br>០២ - ០៣ រសៀល<br>(រយៈពេលជាមធ្យម ១ម៉ ឬជាង១ម៉) | នាយកដ្ឋានអយ្យការ និងកិច្ចការព្រហ្មទណ្ឌក្រសួងយុត្តិធម៌ នៃក្រសួងយុត្តិធម៌ (MoJ) |
| ២ | ២៥/០៥/២០២១<br>០២ - ០៣ រសៀល<br>(រយៈពេលជាមធ្យម ១ម៉ ឬជាង១ម៉) | នាយកដ្ឋានប៉ូលីសប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន (DAHTJP) នៃក្រសួងមហាផ្ទៃ (MoI) |
| ៣ | ២៦/០៥/២០២១<br>០៣ - ០៤ រសៀល<br>(រយៈពេលជាមធ្យម ១ម៉ ឬជាង១ម៉) | គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)-(NCCT) |
| ៤ | ២៦/០៥/២០២១<br>០៤ - ០៥ រសៀល<br>(រយៈពេលជាមធ្យម ១ម៉ ឬជាង១ម៉) | នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(MoSVY) |
| ៥ | ២៦/០៥/២០២១<br>០៣ - ០៤ រសៀល<br>(រយៈពេលជាមធ្យម ១ម៉ ឬជាង១ម៉) | នាយកដ្ឋានទទួលបន្ទុកអធិការកិច្ចការងារ នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម និងនាយកដ្ឋានការងារកុមារ នៃក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ (MoLVT) |
| ៦ | ២៩/០៥/២០២១<br>០២ - ០៣ រសៀល<br>(រយៈពេលជាមធ្យម ១ម៉ ឬជាង១ម៉) | នាយកដ្ឋាននីតិកម្ម នៃក្រសួងអប់រំ យុវជន និងកីឡា (MoEYS) |